អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C




សូមស្កេនQR Code

គំនូរជីវចល

ធនធានបង្រៀន

Written by TukTuk

Illustrated by Choven Hen

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C



រតនានិងមករាជាបងប្អូននឹងគ្នា។ ថ្ងៃមួយ កុមារទាំងពីរកំពុងលេងជាមួយមិត្តភក្តិនៅក្បែរផ្ទះដូចសព្វមួយដង។
រតនាសួរ « ហ្អេ! តើពួកឯងធ្លាប់ឃើញយក្សចម្លែកទេ? »
មករាឆ្លើយ « ខ្ញុំមិនដែលឃើញទេ បងប្រាប់ខ្ញុំផងមើល! »
រតនាតបវិញ « គាត់បើករ៉ឺម៉កកង់បី ហើយគ្រប់គ្នាហៅគាត់ថា យក្ស »។
មករាសួរទៀត « មាឌគាត់ធំទេ? »

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C



រតនាឆ្លើយ « បងឮគេថាមាឌគាត់ធំ ហើយខ្ពស់ប៉ុនដើមត្នោតហ្ន៎ ហើយស្បែកជើងគាត់ធំប៉ុនទូក... »



ហើយគាត់ចូលចិត្តញុំាក្មេងៗជាអាហារ។
មករាភ្លាត់មាត់ « អ្ហ៊ា ញុំាក្មេងៗ! ខ្ញុំមិនចង់ជួបគាត់ទេ »។



ថ្ងៃមួយ រតនានិងមករាបានបែកកង់ពេលកំពុងជិះតាមផ្លូវពីសាលារៀន
ត្រឡប់ទៅផ្ទះវិញ។
រតនានិងមករាមិនដឹងធ្វើយ៉ាងម៉េច ក៏អង្គុយចាំនៅតាមផ្លូវក្បែរមាត់ទឹក
រង់ចាំក្រែងលោមាននរណាម្នាក់ជិះកាត់ ដើម្បីសុំដោយសារ។



មិនយូរប៉ុន្មាន រ៉ឺម៉កកង់បីមួយបានបើកមកដល់។ កុមារទាំងពីរបក់ដៃឃាត់រ៉ឺម៉កកង់បី។
រ៉ឺម៉កកង់បីនោះមានពណ៌ខៀវ ហើយអ្នកបើកក៏ពាក់មួកការពារសុវត្ថិភាពពណ៌ខៀវដែរ។
នៅបាំងខាងក្រោយមានសត្វអ្វីម៉្យាងដែលកុមារទាំងពីរមិនដែលស្គាល់។
រតនានិងមករាមានអារម្មណ៍ភ័យតិចៗ។



ពេលដែលរ៉ឺម៉កកង់បីឈប់ រតនានិងមករាសង្កេតឃើញថា អ្នកបើករ៉ឺម៉កកង់បីមានជើងធំណាស់។



ពេលដែលគាត់ចុះពីលើរ៉ឺម៉កកង់បី គាត់ឈរខ្ពស់ឡើងជង្រ្គោង។
រតនានិងមករាកាន់តែភ័យថែមទៀត។



អ្នកបើករ៉ឺម៉កកង់បីដោះមួកការពារសុវត្ថិភាពចេញ...



...គាត់មានមុខចម្លែកខ្លាំងណាស់!
រតនានិងមករាភិតភ័យកាន់តែខ្លាំង។



អ្នកបើករ៉ឺម៉កកង់បីនិយាយទាំងសម្លេងធំៗ « សួស្តី! ខ្ញុំឈ្មោះយ៉េក! មានអ្វីឱ្យខ្ញុំជួយទេ? » រតនានិងមករាងើយមុខមើលទៅយ៉េក ហើយខ្សឹបគ្នា « តើគាត់និយាយថាគាត់ឈ្មោះយក្សមែនទេ? អ្ហឺយ! ខ្ញុំគិតថាយើងគួរតែរត់ទៅល្អជាង »។



យ៉េក ឮអ្វីដែលក្មេងៗខ្សឹបគ្នា។
គាត់តប « កុំបារម្ភអីណាក្មេងៗ! ខ្ញុំមិនមែនជា យក្សទេ!
ខ្ញុំឈ្មោះយ៉េកទេតើ »។ រតនានិងមករានៅតែភ័យខ្លាចដដែល។



អ្នកដែលអង្គុយនៅបាំងខាងក្រោយរ៉ឺម៉កកង់បីក៏ចុះមក « សួស្តី!
ខ្ញុំឈ្មោះខេទី! ខ្ញុំគឺជាសត្វ ខូអាឡា! តើអ្នកទាំងពីរឈ្មោះអ្វីដែរ? »
រតនាតបវិញ « ខ្ញុំមិនអាចប្រាប់ឈ្មោះរបស់ខ្ញុំទៅអ្នកបានទេ
ព្រោះថា អ្នកគឺជាមនុស្សចម្លែក... » រតនានិងមករាកាន់តែភ័យខ្លាំងឡើងៗ។
កុមារទាំងពីរមិនដឹងធ្វើយ៉ាងម៉េច ដើម្បីរត់គេចឱ្យឆ្ងាយពីមនុស្សចម្លែកទាំងពីរនាក់នោះទេ។



« ពីបៗ! ពីបៗ! »
ពួកគេបានឮសំឡេងស៊ីប្លេម៉ូតូ ហើយបុរសម្នាក់ក៏បន្លឺសំឡេងឡើង« សួស្តី យ៉េក! សួស្តី ខេទី! សួស្តីក្មេងៗ! ទាំងអស់គ្នាសុខសប្បាយជាទេ? » មករា ងាកទៅទាំងភ្ញាក់ផ្អើល « អូ! លោកគ្រូតើ! ជម្រាបសួរលោកគ្រូ តើលោកគ្រូស្គាល់យ៉េកនិងខេទីដែរមែនទេ? »
លោកគ្រូសុខឆ្លើយ « បាទស្គាល់! ពួកយើងគឺជាមិត្តភក្តិនឹងគ្នាទៀតផង »។



លោកគ្រូសុខសួរមករានិងរតនា « តើអ្នកទាំងពីរនាក់កំពុងធ្វើអ្វីហ្នឹង? »
រតនាឆ្លើយ « ចាសលោកគ្រូ កង់របស់ខ្ញុំបានបែក ហើយពួកខ្ញុំកំពុងរង់ចាំក្រែងមានអ្នកណាម្នាក់មក
ជួយពួកខ្ញុំហ្នឹងណា ហើយយ៉េកនិងខេទីក៏បានមកដល់ »។ មករាលួចសួរលោកគ្រូសុខខ្សឹបៗ
« លោកគ្រូៗ! តើយ៉េកចូលចិត្តញ៉ាំក្មេងៗជាអាហារមែនទេ? »
លោគ្រូសុខឆ្លើយទាំងអស់សំណើច « អត់ទេ! អត់ទេ! វាមិនមែនជាការពិតនោះទេ »។



យ៉េកញូដូចនេះ ក៏និយាយត « កុំយល់ច្រឡំនឹងខ្ញុំអី! ខ្ញុំមិនចូលចិត្តញ៉ាំក្មេងៗទេ
តែខ្ញុំចូលចិត្តញ៉ាំភីហ្សានិងផ្លែឪឡឹក »។
ទាំងអស់គ្នាសើចគឹល... « ហាសហា ហិហិ »។



យ៉េកសួររតនានិងមករា « តើអ្នកទាំងពីរឈ្មោះអ្វីដែរ? »
កុមារទាំងពីរឆ្លើយបន្តបន្ទាប់គ្នា « ខ្ញុំឈ្មោះ រតនា ចំណែកខ្ញុំឈ្មោះ មករា »។
យ៉េកបន្ត « អូ! រីករាយណាស់ដែលបានស្គាល់ រតនានិងមករា! ចាំខ្ញុំជូនអ្នកទាំងពីរទៅផ្ទះណា៎! »



ទាំងអស់គ្នាក៏ជម្រាបលាលោកគ្រូសុខ។ យ៉េកបានចងកង់របស់រតនានិងមករា នៅពីក្រោយរ៉ឺម៉កកង់បី។ បន្ទាប់មក កុមារទាំងពីរក៏ឡើងលើរ៉ឺម៉កកង់បី ហើយយ៉េក ក៏បើកវាចេញទៅ។ រតនានិងមករាជជែកលេង ជាមួយ ខេទីតាមផ្លូវរហូតដល់ផ្ទះ។ ខេទីបាននិយាយប្រាប់កុមារទាំងពីរអំពីប្រទេស អូស្ត្រាលីដែលជាកន្លែង កំណើតរបស់គាត់និងយ៉េក។ រតនានិងមករាមានសំណួរជាច្រើនដែលចង់សួរទៅកាន់គាត់ ប៉ុន្តែពេលវេលាខ្លីពេក រ៉ឺម៉កកង់បីក៏បានទៅដល់ផ្ទះរបស់ពួកគេ។

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C



រតនានិងមករាលោតចុះពីលើរ៉ឺម៉កកង់បី
« អរគុណច្រើន យ៉េកនិងខេទី! ថ្ងៃក្រោយជួបគ្នា! »
ហើយរតនានិងមករាក៏រត់ទៅលេងជាមួយមិត្តភក្តិរបស់ពួកគេបាត់ទៅ។



រតនាបានប្រាប់មិត្តភក្តិរបស់ពួកគេ « ពួកខ្ញុំបានជួបយក្សចម្លែកនោះហើយ មាឌគាត់ធំ
ហើយខ្ពស់មែន តែមិនមែនខ្ពស់ដូចជាដើមត្នោតនោះទេ ស្បែកជើងគាត់ក៏ធំដែរ
តែមិនមែនធំប៉ុនទូកនោះទេ ហើយគាត់ក៏មិនមែនញ៉ាំក្មេងៗជាអាហារដែរ
តែគាត់ចូលចិត្តញ៉ាំភីហ្សានិងផ្លែឪឡឹកតែប៉ុណ្ណោះ គាត់ឈ្មោះថា យ៉េក មិនមែនឈ្មោះថា យក្សនោះទេ
មិត្តភក្តិរបស់គាត់ឈ្មោះ ខេទី គឺជាសត្វ ខូអាឡា ហើយពួកគេក៏ជាមិត្តភក្តិរបស់លោកគ្រូសុខផងដែរ »។



មករាបន្តទៀត « ខ្ញុំចង់ជួបពួកគាត់ម្តងទៀតក្នុងពេលឆាប់ៗនេះ »។
ក្មេងៗទាំងអស់ក៏បន្ថែម « មែនហើយៗ! សូម្បីតែពួកយើងក៏ចង់ជួបពួកគាត់ដែរ »៕